ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងការបរទេស
និងសហប្រតិបត្តិការអន្តរជាតិ

# ឯកឧត្តម ឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន កោតសរសើរ ការរួមចំណែករបស់អូស្ត្រាលីក្នុងដំណើរការសន្តិភាពរបស់កម្ពុជា

**ឯកឧត្តម ប្រាក់ សុខុន** ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីការបរទេស និងសហប្រតិបត្តិការអន្តរជាតិ បានថ្លែងកោតសរសើរចំពោះការរួមចំណែកយ៉ាងសំខាន់របស់អូស្ត្រាលី ជាពិសេសរបស់ **ឯកឧត្តម ឧត្តមសេនីយ៍ឯក ចន សេនដឺសុន** (Jonh Sanderson) ក្នុងតួនាទីពេលនោះជាមេបញ្ជាការរបស់កងកម្លាំងអន្តរជាតិនៃអាជ្ញាធរបណ្តោះអាសន្នអង្គការសហប្រជាជាតិប្រចាំកម្ពុជា (UNTAC) នៅក្នុងដំណើរការសន្តិភាពនៅកម្ពុជា។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានរំលឹកឡើងវិញនូវសមិទ្ធផលនានាដែល UNTAC សម្រេចបាននៅកម្ពុជា ក្នុងការអនុវត្តគោលដៅសំខាន់នៃកិច្ចព្រមព្រៀងទីក្រុងប៉ារីស រួមទាំងការរៀបចំការបោះឆ្នោតសកលនៅឆ្នាំ១៩៩៣ បើទោះបីជាមានការធ្វើពហិការរបស់ក្រុមខ្មែរក្រហម និងការបន្តសង្គ្រាមបែបឧទ្ទាមរបស់ពួកនេះក៏ដោយ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានគូសបញ្ជាក់ថា ក្រោយការដកចេញពីកម្ពុជារបស់ UNTAC **សម្តេចតេជោនាយករដ្ឋមន្ត្រី** បានដាក់ចេញនូវគោលនយោបាយឈ្នះ-ឈ្នះ ដែលបាននាំមកនូវការបង្រួបបង្រួមជាតិ សន្តិភាពពេញលេញ និងស្ថិរភាពទាំងស្រុងនៅក្នុងប្រទេស នៅឆ្នាំ១៩៩៨។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានលើកឡើងបែបនេះក្នុងជំនួបនៅថ្ងៃទី២៦ ខែមេសា ឆ្នាំ២០២២ នៅទីស្តីការក្រសួង ជាមួយឯកឧត្តមឧត្តមសេនីយ៍ឯក **ចន សេនដឺសុន** អតីតមេបញ្ជាការរបស់កងកម្លាំងអន្តរជាតិ UNTAC អតីតមេបញ្ជាការកងទ័ពអូស្ត្រាលី និងជាអតីតអភិបាលរដ្ឋ Western Australia ដែលអញ្ជើញមកបំពេញទស្សនកិច្ចនៅកម្ពុជា ដើម្បីអបអរសាទរខួបអនុស្សាវរីយ៍លើកទី៧០ នៃទំនាក់ទំនងការទូតកម្ពុជា-អូស្ត្រាលី និងខួបអនុស្សាវរីយ៍លើកទី៣០ នៃការបង្កើត UNTAC ផងដែរ ។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** បានគូសបញ្ជាក់ពីការសម្រេចបាននូវការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមនៅកម្ពុជា ដោយមានប្រសាសន៍ថា កំណើនផលិតផលក្នុងស្រុកសរុបប្រចាំឆ្នាំជាមធ្យមលើសពី ៧% ក្នុងរយៈពេលពីរទស្សវត្សរ៍កន្លងមក បានធ្វើឱ្យប្រទេសកម្ពុជាងើបចេញពីប្រទេសមានចំណូលទាប ទៅជាប្រទេសមានចំណូលមធ្យមកម្រិតទាប នៅក្នុងឆ្នាំ២០១៥។ **ឯកឧត្តម** បានថ្លែងអំណរគុណចំពោះការចូលរួមចំណែករបស់ប្រទេសអូស្ត្រាលី ក្នុងការអភិវឌ្ឍសេដ្ឋកិច្ច-សង្គមនៅកម្ពុជា។

អាសយដ្ឋាន: លេខ ៣ វិថី **សម្តេច ហ៊ុន សែន**
សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន
រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ : (855) 23 216 122
ទូរសារ : (855) 23 216 141, 023 213 341
អ៊ីម៉ែល : mfaic@mfaic.gov.kh

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានជម្រាបជូន **ឧត្តមសេនីយ៍ឯក សេនជីសុន** ផងដែរ អំពីមោទនភាពរបស់កម្ពុជា ក្នុងការប្រែក្លាយពីប្រទេសដែលទទួលយកកងកម្លាំងថែរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ ទៅជាប្រទេសមួយដែលរហូតមកដល់ពេលនេះ បានបញ្ជូនកងកម្លាំងកម្ពុជាជាង ៨ពាន់នាក់ ទៅចូលរួមក្នុងបេសកកម្មថែរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិ នៅប្រទេសចំនួន៨ នៅទ្វីបអាហ្វ្រិក និងមជ្ឈឹមបូព៌ា។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** និង**ឧត្តមសេនីយ៍ឯក សេនជីសុន** បានសម្តែងការពេញចិត្តចំពោះមិត្តភាព និងកិច្ចសហប្រតិបត្តិការដ៏ល្អប្រសើរ និងយូរអង្វែង ចាប់តាំងពីការបង្កើតទំនាក់ទំនងការទូតរវាងប្រទេសទាំងពីរ នៅក្នុងឆ្នាំ១៩៥១ មក។

**ឯកឧត្តមឧត្តមសេនីយ៍ឯក សេនជីសុន** បានសម្តែងនូវការកោតសរសើរយ៉ាងជ្រាលជ្រៅចំពោះការអភិវឌ្ឍដ៏ឆាប់រហ័សនៅកម្ពុជា និងបានកោតសរសើររាជរដ្ឋាភិបាលកម្ពុជាចំពោះយុទ្ធនាការចាក់វ៉ាក់សាំងប្រកបដោយជោគជ័យ ក៏ដូចជាការបញ្ជូនកងកម្លាំងកម្ពុជារាប់ពាន់នាក់ទៅចូលរួមក្នុងប្រតិបត្តិការរក្សាសន្តិភាពរបស់អង្គការសហប្រជាជាតិនៅប្រទេសផ្សេងៗគ្នាជុំវិញពិភពលោក។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** បានជម្រាបជូនដៃគូសន្ទនារបស់ឯកឧត្តមអំពីលទ្ធផលនៃដំណើរទស្សនកិច្ចជាលើកដំបូងរបស់ឯកឧត្តមទៅកាន់ប្រទេសមីយ៉ាន់ម៉ាកាលពីខែមីនា ដោយគូសបញ្ជាក់អំពីបញ្ហាប្រឈមនានា ជាពិសេសភាពស្មុគស្មាញសម្រាប់កិច្ចសន្ទនាស្វែងរកសន្តិភាពក្នុងចំណោមភាគីពាក់ព័ន្ធទាំងអស់។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** បានសង្កត់ធ្ងន់លើអាទិភាពបន្ទាន់ចំនួនបីគឺ ៖ (១) ការបោះជំហានឆ្ពោះទៅរកការបញ្ចប់អំពើហិង្សា (២) ការសម្របសម្រួលការចែកចាយជំនួយមនុស្សធម៌ និង (៣) ការកសាងទំនុកចិត្ត និងការបង្កើតបរិយាកាសដែលចាំបាច់សម្រាប់កិច្ចសន្ទនានយោបាយ។ **ឯកឧត្តមឧបនាយករដ្ឋមន្ត្រី** ក៏បានលើកឡើងផងដែរអំពីផែនការរបស់ឯកឧត្តមក្នុងការរៀបចំកិច្ចប្រជុំពិគ្រោះយោបល់ស្តីពីជំនួយមនុស្សធម៌ នៅរាជធានីភ្នំពេញ ដើមខែឧសភា ឆ្នាំ ២០២២ ខាងមុខនេះ។

**ឯកឧត្តមឧត្តមសេនីយ៍ឯក សេនជីសុន** បានកោតសរសើរចំពោះកិច្ចខិតខំប្រឹងប្រែងរបស់**សម្តេចតេជោនាយករដ្ឋមន្ត្រី ហ៊ុន សែន** ក្នុងឋានៈជាប្រធានអាស៊ាន និងរបស់**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី**ផ្ទាល់ក្នុងឋានៈជាប្រេសិតពិសេសរបស់ប្រធានអាស៊ានសម្រាប់មីយ៉ាន់ម៉ា ក្នុងការស្វែងរកដំណោះស្រាយសម្រាប់វិបត្តិបច្ចុប្បន្ននៅមីយ៉ាន់ម៉ា ជាពិសេសតាមរយៈការប្រើប្រាស់បទពិសោធន៍របស់កម្ពុជា។

**ឯកឧត្តមឧបនាយករដ្ឋមន្ត្រី ប្រាក់ សុខុន** និង**ឯកឧត្តមឧត្តមសេនីយ៍ឯក សេនជីសុន** ក៏បានពិភាក្សាអំពីបញ្ហាតំបន់ និងអន្តរជាតិមួយចំនួនដែលជាកង្វល់រួមផងដែរ៕

ថ្ងៃអង្គារ ១០រោច ខែចេត្រ ឆ្នាំខាល ចត្វាស័ក ព.ស.២៥៦៥
រាជធានីភ្នំពេញ ថ្ងៃទី ២៦ ខែ មេសា ឆ្នាំ ២០២២